ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤

## សម្រេច

**មាត្រាមួយ .-**

មាត្រា១ មាត្រា២ មាត្រា១០ មាត្រា១២ និងមាត្រា១៥ នៃអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា១ .- ថ្មី**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ក.ផ.ផ.** ដើម្បីធ្វើការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ពង្រឹងនិងពង្រីកបទពិសោធនៃការអភិវឌ្ឍ និងភាពទាក់ទាញទេសចរណ៍ តាមរយៈការពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជា ជំរុញកិច្ចសហការភាពជាដៃគូនិងការចូលរួមរវាងផ្នែកសាធារណៈនិងផ្នែកឯកជនក្នុងការធានាគុណភាពសេវាកម្មនិងផលិតផលទេសចរណ៍ក្នុងការផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ។

**មាត្រា២ .- ថ្មី**

**ក.ផ.ផ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ វិភាគស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយពីទីផ្សារទេសចរណ៍
- ផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ
- ពង្រឹងនិងពង្រីកការចូលរួមគាំទ្រតាមគ្រប់រូបភាព រួមមានគំនិតផ្តួចផ្តើមរួមគ្នា ការចែករំលែកធនធាន ការផ្លាស់ប្តូរចំណេះដឹង ខាងផ្នែកសាធារណៈ ផ្នែកឯកជន និងដៃគូអភិវឌ្ឍលើការផ្សព្វផ្សាយនិងការអភិវឌ្ឍទេសចរណ៍កម្ពុជា
- សម្របសម្រួលជំរុញការផ្សព្វផ្សាយទាក់ទងនឹងវិស័យទេសចរណ៍ ដែលធ្វើឡើងដោយផ្នែកសាធារណៈ និងផ្នែកឯកជន
- ចូលរួមសម្របសម្រួលនិងជំរុញសកម្មភាពទាក់ទងនឹងទេសចរណ៍ ដែលរៀបចំឡើងដោយផ្នែកសាធារណៈ និងផ្នែកឯកជន តាមរយៈការផ្តល់អនុសាសន៍ គំនិតច្នៃប្រឌិត ជំនួយ និងការផ្តល់ធនធានចាំបាច់របស់ **ក.ផ.ផ.**
- ចូលរួមយ៉ាងសកម្មក្នុងការប្រឹក្សាយោបល់លើការរៀបចំនិងអនុវត្តគម្រោង គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព
- ចូលរួមជំរុញការរៀបចំព្រឹត្តិការណ៍ ពិព័រណ៍ ពិធីបុណ្យ និងគំនិតផ្តួចផ្តើមទេសចរណ៍ផ្សេងទៀត
- សហការសម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធ លើការលើកកម្ពស់គុណភាពសេវាកម្ម និងជំរុញផលិតផលទេសចរណ៍
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា១០ .- ថ្មី**

**ក.ផ.ផ.** អាចបង្កើតគណៈកម្មការនានានិងក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន។

សមាសភាព តួនាទី និងភារកិច្ចនៃគណៈកម្មការនានានិងក្រុមការងារជំនាញនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ផ.ផ.** ឬសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១២ .- ថ្មី**

**ក.ផ.ផ.** ត្រូវមានអង្គភាពប្រតិបត្តិមួយដែលគ្រប់គ្រងដោយនាយកប្រតិបត្តិ១(មួយ)រូប។

នាយកប្រតិបត្តិ ត្រូវជាបុគ្គលដែលមានសញ្ជាតិខ្មែរនិងមិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។ លក្ខណសម្បត្តិផ្សេងទៀតរបស់នាយកប្រតិបត្តិត្រូវកំណត់ក្នុងលក្ខន្តិកៈរបស់ **ក.ផ.ផ.**។

នាយកប្រតិបត្តិត្រូវតែងតាំងឬបញ្ចប់មុខតំណែងដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ផ.ផ.**។

តួនាទីនិងភារកិច្ចរបស់នាយកប្រតិបត្តិ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ផ.ផ.**។

សមាសភាព តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពប្រតិបត្តិនៃ **ក.ផ.ផ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ផ.ផ.**។

## មាត្រា១៥ .- ថ្មី

**ក.ផ.ផ.** ត្រូវអនុម័តនីតិវិធីជាលាយលក្ខណ៍អក្សរ ដើម្បីកំណត់នូវបៀវត្ស លាភការ ថ្លៃបំពេញការងារ និងការចំណាយផ្សេងៗ ដែលត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬសេចក្តីសម្រេចរបស់ **ក.ផ.ផ.**។

## មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

## មាត្រាបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ